# គោលការណ៍ស្តីពីជំនួយផ្នែកហិរញ្ញវត្ថុអ្នកជំងឺរបស់ Fred Hutch Cancer Center ឧបសម្ព័ន្ធទី III - សាលកបត្រព័ត៌មានអំពីចំនួនទឹកប្រាក់ដែលចេញវិក្កយបត្រជាទូទៅ (AGB)

Fred Hutch Cancer Center កំណត់ចំនួនទឹកប្រាក់ដែលចេញវិក្កយបត្រជាទូទៅ (Amounts Generally Billed, AGB) ជារៀងរាល់ឆ្នាំដោយប្រើ "វិធីសាស្ត្របែរមើលក្រោយ" ដែលបានពណ៌នាស្របតាមបទបញ្ញត្តិរតនាគារផ្នែកទី 1.501(r)- 5(b)(1)។

## 1. ការគណនា AGB៖

- ជារៀងរាល់ឆ្នាំ ផ្នែកហិរញ្ញវត្ថុ (Finance Department) របស់ Fred Hutch Cancer Center ប្រមូលទិន្នន័យលើរាល់ការទាមទារសំណងទាំងអស់សម្រាប់ឆ្នាំសារពើពន្ធដែលមានសមតុល្យដែលទទួលបានចុងក្រោយចំនួន <$1000 ។
- នេះរួមបញ្ចូលទាំងការទាមទារសំណងដែលមានកាលបរិច្ឆេទចេញពីមន្ទីរពេទ្យ សម្រាប់ឆ្នាំសារពើពន្ធមុន។ ឆ្នាំសារពើពន្ធដំបូងរបស់ Fred Hutch Cancer Center គឺនៅថ្ងៃទី 1 ខែកក្កដា រហូតដល់ថ្ងៃទី 30 ខែមិថុនា។
- ការទាមទារសំណងអំពីការទូទាត់ប្រាក់ដោយខ្លួនឯងមិនត្រូវបានរាប់បញ្ចូលឡើយ។
- ភាគរយ AGB ប្រចាំឆ្នាំរបស់ Fred Hutch Cancer Center គឺស្មើនឹងចំនួន ទឹកប្រាក់សរុបដែលបានបង់ដោយអ្នកបង់ប្រាក់ជាភាគីទីបី ដែលបានបែងចែកដោយផលបូកនៃថ្លៃសេវាសរុបដែលពាក់ព័ន្ធសម្រាប់ការទាមទារសំណងទាំងនោះនៅក្នុងអំឡុងពេលឆ្នាំសារពើពន្ធមុន។

**ការគណនាត្រូវបានសង្ខេបដូចខាងក្រោម៖**

AGB% = ការបង់ប្រាក់ជានារ៉ាប់រងឆ្នាំសារពើពន្ធមុន/ការគិតថ្លៃសរុប

## 2. រយៈពេល និងការប្រើប្រាស់ AGB៖

- ផ្នែកហិរញ្ញវត្ថុរបស់ Fred Hutch Cancer Center នឹងកំណត់ភាគរយ AGB បច្ចុប្បន្ន ហើយ Fred Hutch Cancer Center នឹងចាប់ផ្តើមអនុវត្តភាគរយ AGB បច្ចុប្បន្ននៅក្នុងរយៈពេល 120 ថ្ងៃ នៅចុងឆ្នាំសារពើពន្ធនីមួយៗ។
- អ្នកជំងឺដែលចាត់ទុកថាមានសិទ្ធិទទួលបានជំនួយផ្នែកហិរញ្ញវត្ថុស្របតាមគោលការណ៍ស្តីពីជំនួយផ្នែកហិរញ្ញវត្ថុរបស់អ្នកជំងឺរបស់ Fred Hutch Cancer Center

នឹងមិនត្រូវបានគិតថ្លៃលើសពីចំនួនទឹកប្រាក់ដែលចេញវិក្កយបត្រជាទូទៅ (“AGB”) ដល់បុគ្គលដែលមានការគ្របដណ្តប់ដោយធានារ៉ាប់រងឡើយ។ អ្នកជំងឺដែលមានសិទ្ធិទទួលបាន ដែលមានការគ្របដណ្តប់លើធានារ៉ាប់រង នឹងមិនមានការទទួលខុសត្រូវដោយផ្ទាល់ក្នុងការទូទាត់ប្រាក់ច្រើនជាង AGB បន្ទាប់ពីការទូទាត់ប្រាក់ទាំងអស់ដោយក្រុមហ៊ុនធានារ៉ាប់រងសុខភាពបានបង់នោះឡើយ។

3. AGB របស់ Fred Hutch Cancer Center គឺ **44.94% ចូលជាធរមាន**នៅថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2024 (ផ្អែកលើទិន្នន័យទាមទារសំណងឆ្នាំសារពើពន្ធ 2024)។